**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ១៨,០០ ហិកតា នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៧៨/១៧ អបខ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតលេខ ៣៨៦៨ កសក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ១៨,០០ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែងទំហំ ១៧,៣០ ហិកតា និងផ្ទៃដីទំហំ ០,៧០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិមន **ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន **៣៧** គ្រួសារ នៅភូមិមន **ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៣** : ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន **៥១** ក្បាលដី ជូនប្រជាពលរដ្ឋ **៣៧** គ្រួសារ ស្ថិតនៅភូមិមន **ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...........ចុះថ្ងៃទី.......ខែ.........ឆ្នាំ២០១៧ ស្ដីពីការកាត់ឆ្វៀលដីសរុបទំហំ ១៨,០០ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៧គ្រួសារ ឆ្វៀលដីទំហំ ១៧,៣០ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង និងដីទំហំ ០,៧០ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិមន ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ




កំពង់ស្ពឺ,ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ...........ដនសស.កស្ព
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ

តាប់ ម៉ាឡៀ

លេខ...........
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧
អភិបាលនៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

ខ្វី សំណាង

ឧបសម្ព័ន្ធ....... ចំណុចនិយាមកាព្រំដី ដែលស្នើសុំកាត់ចេញពីដែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៧គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំផ្ទះជាក់ស្តែង
ស្ថិតនៅភូមិមន ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

តារាងចំណុចនិយាមកា

Projection UTM, Zone 48N, Datum WGS 84

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 441395 | 1255625 | 44 | 441459 | 1255055 |
| 2 | 441325 | 1255629 | 45 | 441456 | 1255029 |
| 3 | 441327 | 1255670 | 46 | 441481 | 1255026 |
| 4 | 441272 | 1255657 | 47 | 441529 | 1255015 |
| 5 | 441266 | 1255684 | 48 | 441562 | 1255010 |
| 6 | 441228 | 1255670 | 49 | 441592 | 1255005 |
| 7 | 441230 | 1255650 | 50 | 441621 | 1255003 |
| 8 | 441237 | 1255650 | 51 | 441628 | 1255042 |
| 9 | 441234 | 1255603 | 52 | 441626 | 1255053 |
| 10 | 441182 | 1255595 | 53 | 441617 | 1255052 |
| 11 | 441181 | 1255573 | 54 | 441619 | 1255089 |
| 12 | 441160 | 1255574 | 55 | 441622 | 1255124 |
| 13 | 441161 | 1255554 | 56 | 441621 | 1255144 |
| 14 | 441157 | 1255543 | 57 | 441620 | 1255162 |
| 15 | 441157 | 1255524 | 58 | 441618 | 1255184 |
| 16 | 441166 | 1255518 | 59 | 441645 | 1255183 |
| 17 | 441166 | 1255486 | 60 | 441643 | 1255198 |
| 18 | 441167 | 1255468 | 61 | 441646 | 1255213 |
| 19 | 441171 | 1255457 | 62 | 441653 | 1255249 |
| 20 | 441172 | 1255449 | 63 | 441638 | 1255250 |
| 21 | 441205 | 1255443 | 64 | 441640 | 1255272 |
| 22 | 441207 | 1255397 | 65 | 441641 | 1255300 |
| 23 | 441241 | 1255397 | 66 | 441643 | 1255329 |
| 24 | 441242 | 1255360 | 67 | 441643 | 1255339 |
| 25 | 441254 | 1255352 | 68 | 441645 | 1255354 |
| 26 | 441257 | 1255338 | 69 | 441567 | 1255357 |
| 27 | 441252 | 1255316 | 70 | 441566 | 1255367 |
| 28 | 441239 | 1255312 | 71 | 441558 | 1255366 |
| 29 | 441238 | 1255253 | 72 | 441518 | 1255365 |
| 30 | 441269 | 1255256 | 73 | 441516 | 1255392 |
| 31 | 441280 | 1255257 | 74 | 441517 | 1255402 |
| 32 | 441281 | 1255244 | 75 | 441496 | 1255402 |
| 33 | 441320 | 1255241 | 76 | 441495 | 1255441 |
| 34 | 441339 | 1255239 | 77 | 441457 | 1255440 |
| 35 | 441345 | 1255219 | 78 | 441444 | 1255440 |
| 36 | 441335 | 1255192 | 79 | 441437 | 1255442 |
| 37 | 441322 | 1255164 | 80 | 441439 | 1255492 |
| 38 | 441324 | 1255150 | 81 | 441436 | 1255518 |
| 39 | 441326 | 1255143 | 82 | 441429 | 1255539 |
| 40 | 441327 | 1255133 | 83 | 441426 | 1255559 |
| 41 | 441331 | 1255111 | 84 | 441424 | 1255579 |
| 42 | 441336 | 1255077 | 85 | 441394 | 1255589 |
| 43 | 441336 | 1255072 | | | |

កំពង់ស្ពឺ.ថ្ងៃទី..២៨..... ខែ..៥.១..... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ..២៣១៩......ជនសស.កស្ត
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ.ថ្ងៃទី.......... ខែ..... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តកំពង់ស្ពឺ

តាប់ ម៉ាឡៃ

លេខ..២៧៥៤/១៧.សជរ
បានឃើញ និងឯកភាព
កំពង់ស្ពឺ.ថ្ងៃទី..២៨.. ខែ....១..... ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការរៀបចំដែនដី ខេត្តកំពង់ស្ពឺ

ឃុត សំណាង